Drug Court of
New South Wales

# តុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើ ឱសថញៀននៃរដ្ឋញូវសោវែល (Drug Court of NSW) មគ្គុទ្ទេសក៍ក្នុងការបញ្ជូនបន្តបុគ្គលនានាដែលមានសិទ្ធិទទួល

## ការបញ្ជូនបន្តបុគ្គលនានា ដែលមានសិទ្ធិទទួលទៅ តុលាការដោះស្រាយបញ្ហាទាក់ ទងនឹងការប្រើឱសថញៀនទៅ (Drug Court)

តុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀននៃរដ្ឋញូសោវែល (The Drug Court of NSW) គឺជាតុលាការឯកទេស ដែល រៀបចំការប្រជុំជាផ្លូវការនៅ Parramatta, Hunter, Sydney CBD និង Dubbo។ តុលាការនេះមើលការខុសត្រូវលើការធ្វើនីតិសម្បទា អ្នកប្រព្រឹត្តិបទល្មើសដែលពឹងផ្អែកលើឱសថញៀនដែលមានសិទ្ធិទទួលបាន ('បុគ្គលនានាដែលមានសិទ្ធិទទួល')។ ជាជាងការដាក់ ពន្ធនាគារ ពេញរយៈពេល អ្នកប្រព្រឹត្តិបទល្មើសទាំងនេះចូលរួម ក្នុងកម្មវិធី របស់តុលាការដោះស្រាយ បញ្ហាទាក់ទងនឹងការប្រើ ឱសថញៀន (Drug Court)។

តុលាការនៅតាមតំបន់ និងតុលាការនៅតាមសង្កាត់ មាន កាតព្វកិច្ចធ្វើការសាកសួរ និងបញ្ជូនបន្តបុគ្គលនានាទៅ កម្មវិធីរបស់តុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើ ឱសថញៀន (Drug Court)។ តុលាការនៅតាមតំបន់ និងតុលាការ នៅតាមសង្កាត់ទាំងអស់នៅក្នុងរដ្ឋ NSW ត្រូវតែបញ្ជូនបន្តបុគ្គល នានាដែលមើលទៅមាន សិទ្ធិទទួលបាន និងមានឆន្ទៈ។

មគ្គុទ្ទេសក៍នេះថែងពីកាតព្វកិច្ចនេះ លក្ខណៈវិនិច្ឆ័យនៃ សិទ្ធិទទួលបានដែលពាក់ព័ន្ធ និងដំណើរការនៃការបញ្ជូនបន្ត។

## សិទ្ធិទទួលបាន

**តើបុគ្គលដែលមានសិទ្ធិទទួលជានរណា?**

ដើម្បីមានសិទ្ធិទទួលសម្រាប់តុលាការដោះស្រាយ បញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court) បុគ្គលម្នាក់ត្រូវតែ៖

- ត្រូវបានចោទប្រកាន់ចំពោះបទល្មើស ដែលមានសិទ្ធិទទួល
- បានឆ្លើយសារភាពថាមានកំហុស ឬ បានបង្ហាញថាពួកគេនឹងសារភាព ថាមានកំហុសចំពោះបទល្មើសនោះ។
- ទំនងខ្លាំងថានឹងត្រូវបានប្រកាសទោស ឱ្យជាប់ពន្ធនាគារពេញ ប្រសិនបើត្រូវបានដាក់ទោស
- ពឹងផ្អែកលើការប្រើប្រាស់ឱសថ ញៀនខុសច្បាប់
- មានអាយុ 18 ឆ្នាំ ឬលើសនេះ
- មានឆន្ទៈក្នុងការចូលរួម
- ត្រូវបានបញ្ជូនបន្តទៅតុលាការដោះ ស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថ ញៀន (Drug Court) ដោយតុលាការ នៅតាមតំបន់ ឬតុលាការនៅតាម សង្កាត់នៅក្នុងរដ្ឋ NSW

បុគ្គលនោះក៏ត្រូវតែរស់នៅក្នុងមួយក្នុង ចំណោមតំបន់រដ្ឋាភិបាលនៅតាមមូលដ្ឋាន នានាដូចខាងក្រោម៖

- Bayside, Blacktown, Burwood, Canada Bay, Canterbury-Bankstown, Campbelltown, Cessnock, Cumberland, Dubbo Regional, Fairfield, Georges River, Hawkesbury, Hunters Hill, Inner West, Lake Macquarie, Lane Cove,

## កាតព្វកិច្ចរបស់តុលាការដែលបញ្ជូនបន្ត

វាជាកាតព្វកិច្ចរបស់តុលាការមួយដែលពាក់ព័ន្ធជាមួយបុគ្គលម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទល្មើសមួយ ឬដែលសាលក្រម ត្រូវបានធ្វើឧទ្ធរណ៍។

- ដើម្បីធ្វើការសាកសួរក្នុងការស្វែងរកថាតើបុគ្គលម្នាក់ទំនងជាបុគ្គលដែលមានសិទ្ធិទទួលឬអត់ និង
- ប្រសិនបើដូច្នេះ ដើម្បីស្វែងរកថាតើបុគ្គលនោះមានឆន្ទៈឬអត់ក្នុងការឱ្យគេបញ្ជូនបន្តទៅតុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court) ដែលនឹងត្រូវបានដោះស្រាយជាមួយនឹងបទល្មើស និង
- ប្រសិនបើដូច្នេះ ដើម្បីបញ្ជូនបន្តបុគ្គលនោះទៅតុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court) ដែលនឹងត្រូវបានដោះស្រាយជាមួយនឹងបទល្មើសនោះ (ផ្នែក 6, *ច្បាប់តុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន* (Drug Court) *ឆ្នាំ 1998*)។

កាតព្វកិច្ចនេះអនុវត្តចំពោះតុលាការនៅតាមតំបន់ និងតុលាការនៅតាមសង្កាត់ទាំងអស់ក្នុងរដ្ឋ NSW។ តុលាការដែលបញ្ជូនបន្តត្រូវតែបញ្ជូនបន្តអ្នកប្រព្រឹត្តិបទល្មើសដែលមើលទៅទំនងជាមានសិទ្ធិទទួលបានបើប្រៀបធៀបនឹងលក្ខៈវិនិច្ឆ័យ។ នៅពេលត្រូវបានបញ្ជូនបន្ត តុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court) នឹងវាយតម្លៃពីសិទ្ធិទទួលបាន និងភាពសមស្របរបស់បុគ្គលនោះ។

Liverpool, Maitland, Mosman, Newcastle, North Sydney, Parramatta, Penrith, Port Stephens, Randwick, Ryde, Strathfield, Sydney, the Hills Shire, Waverley, Willoughby ឬ Woollahra។

## តើបទល្មើសមួយណាដែលមានសិទ្ធិទទួលបាន?

បទល្មើសមួយណាដែលមានសិទ្ធិទទួលបាន រួមមានបទល្មើសរដ្ឋទាំងអស់ លើកលែងតែបទល្មើសទាំងនោះដែលទាក់ទងនឹង៖

- ការប្រព្រឹត្តិហិង្សា
- ការបំពារបំពានផ្លូវភេទ ឬ
- បទល្មើសឱសថញៀនដែលអាចចោទប្រកាន់ជាផ្លូវការយ៉ាងតឹងរឹង (ផ្នែក 5(2), ច្បាប់តុលាការ ដោះស្រាយបញ្ហាទាក់ទងនឹង ការប្រើឱសថញៀន (Drug Court) ឆ្នាំ *1998*)។

បទល្មើសកុម្មិនវែល (Commonwealth offences) មិនមានសិទ្ធិទទួលបានទេ។

# ការបញ្ជូនបន្ត

## តើការបញ្ជូនបន្តត្រូវធ្វើឡើងយ៉ាងដូចម្ដេច?

នៅពេលបុគ្គលម្នាក់មើលទៅទំនងជាមានសិទ្ធិទទួលបាន និងមានឆន្ទៈត្រូវបានកំណត់ មន្ត្រីតុលាការនៅតុលាការដែលបញ្ជូនបន្តគួរតែចេញដីកាបង្គាប់៖

- បញ្ជូនបន្តបញ្ហាទៅតុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court) ដែលនៅជិតបំផុតកន្លែង ដែលបុគ្គល នោះរស់នៅ និងសម្គាល់លើក្រដាសស្នាមថា 'បានបញ្ជូនបន្តទៅសន្លឹកឆ្នោតរបស់តុលាការដោះស្រាយបញ្ហា ទាក់ទងនឹងការប្រើឱសថញៀន (Drug Court) នៅឯ [បញ្ជាក់ទីកន្លែង]'។
- ការពន្យាពេលលើបញ្ហាសម្រាប់ការលើកមកនិយាយនៅឯតុលាការដែលបញ្ជូនបន្តនៅថ្ងៃបើកប្រជុំជាផ្លូវការបន្ទាប់ដែលអាចមាន ឬក្រោយថ្ងៃកំណត់សន្លឹកឆ្នោតរបស់តុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court)។ (ថ្ងៃចន្ទ (នៅ Hunter និង Dubbo) និងថ្ងៃព្រហស្បតិ៍ (នៅ Parramatta និង Sydney))។
- ការដោះស្រាយជាមួយនឹងការធានានៅក្រៅឃុំតាមរបៀបធម្មតា.

មន្ត្រីតុលាការត្រូវតែទាក់ទងការិយាល័យចុះឈ្មោះរបស់តុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court) ដែលនៅ ជិតបំផុតកន្លែងដែលបុគ្គលនោះរស់នៅ។ ព័ត៌មានលម្អិតនៃ ការបញ្ជូនបន្តត្រូវតែបានផ្ដល់ឱ្យក្រោយពេលវេលាកំណត់ឈប់ទទួលឬលុបចោល៖

**តុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court) នៅ Parramatta និង Sydney**

- ត្រឹមម៉ោង 12 ថ្ងៃត្រង់ នៅថ្ងៃពុធ នីមួយៗ (សម្រាប់ថ្ងៃកំណត់សន្លឹកឆ្នោតនៅថ្ងៃព្រហស្បតិ៍)

**តុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court) នៅ Hunter និង Dubbo**

- ត្រឹមម៉ោង 12 ថ្ងៃត្រង់ នៅថ្ងៃសុក្រ នីមួយៗ (សម្រាប់ថ្ងៃកំណត់សន្លឹកឆ្នោតនៅថ្ងៃចន្ទ)

ប្រសិនបើការបញ្ជូនបន្តបានជោគជ័យ នោះតុលាការដែលបញ្ជូនបន្តត្រូវតែពន្យាពេលបញ្ហាទាក់ទងនឹងទីកន្លែងនៃ តុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court) លើ កាលបរិច្ឆេទដែលបានបញ្ជាក់នៅក្នុង ការជូនដំណឹងនោះ។ ការធានានៅក្រៅឃុំ នឹងត្រូវបានកំណត់ តាមរបៀបធម្មតាដោយតុលាការដែលបញ្ជូនបន្ត។

ប្រសិនបើការបញ្ជូនបន្តមិនបានជោគជ័យទេ បញ្ហានោះនៅតែស្ថិតនៅឯតុលាការដែលបញ្ជូនបន្ត ដែលនឹងត្រូវដោះស្រាយ។

## ក្រោយសន្លឹកឆ្នោត

បន្ទាប់ពីជោគជ័យនៅក្នុងសន្លឹកឆ្នោត តុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court) នឹងកំណត់ពីសិទ្ធិទទួលបាន និងភាពសមស្រប។ នៅពេលណាដែលចាំបាច់ បញ្ហានឹងត្រូវបានចុះក្នុងបញ្ជីសម្រាប់សវនាការអំពីសិទ្ធិទទួលបាន និងភាពសមស្រប។

នៅពេលបានរកឃើញថាមានសិទ្ធិទទួលបាន និងមានភាពសមស្រប កាលបរិច្ឆេទសាលក្រមដំបូងត្រូវបាន កំណត់ដោយតុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court)។ បុគ្គលនោះត្រូវតែបញ្ចប់សព្វគ្រប់ការបន្សាបគ្រឿងញៀន និងការវាយតម្លៃនៅក្នុងកន្លែង ឃុំឃាំង ហើយផែនការព្យាបាលកំណត់តាមតម្រូវការបុគ្គលផ្ទាល់ខ្លួនត្រូវបានបង្កើតឡើង។

បន្ទាប់មកបុគ្គលដែលមានសិទ្ធិទទួលបាននោះត្រូវបាននាំឱ្យបង្ហាញខ្លួននៅចំពោះមុខតុលាការដោះស្រាយ បញ្ហាទាក់ទងនឹង ការប្រើឱសថញៀន (Drug Court) ដើម្បីបញ្ជាក់ពីការសារភាពថាមានកំហុស។ តុលាការដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court) ដាក់សាលក្រម

បន្ទាប់មកព័ត៌មានលម្អិតទាំងនេះត្រូវបានបញ្ចូលទៅក្នុង ‘សន្លឹកឆ្នោត’។

បញ្ហានានាត្រូវបានរក្សាទុកនៅឯលទ្ធផលនៃការបញ្ជូនបន្ត ដែលកំពុងរង់ចាំរបស់តុលាការដែលបញ្ជូនបន្ត។ ក្រដាសស្នាមតុលាការ មិនគួរត្រូវបានផ្ញើទៅតុលាការ ដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court) នៅចំណុចពេលវេលានេះទេ។

### ‘ថ្ងៃកំណត់សន្លឹកឆ្នោត’

កន្លែងនៅក្នុងកម្មវិធីមានកំណត់អាចរកបាន។ នៅពេលណា ការបញ្ជូនបន្តច្រើនជាងកន្លែងដែលអាចមាន នោះនឹង ត្រូវធ្វើការ ចាប់ឆ្នោតដោយចៃដន្យ។ ការិយាល័យចុះឈ្មោះ របស់តុលាការ ដោះស្រាយបញ្ហាទាក់ទងនឹងការប្រើ ឱសថញៀន (Drug Court registry) នឹងជូនដំណឹងទៅតុលាការ ដែលបញ្ជូនបន្តនូវលទ្ធផល នៃការបញ្ជូនបន្ត។

រឿងនេះកើតឡើងក្រោយកិច្ចប្រជុំរបស់ក្រុមការងារត្រូវបាន បញ្ចប់ ហើយការពិភាក្សាអំពីសន្លឹកឆ្នោតត្រូវបានបញ្ចប់ នៅ ‘ថ្ងៃកំណត់សន្លឹកឆ្នោត’’។

ជាប់ពន្ធនាគារដំបូង និង ចេញដីកា សម្រាប់សាលក្រមព្យួរទោស។ បន្ទាប់មក បុគ្គលនោះត្រូវបានដោះលែងដើម្បីធ្វើកម្មវិធី របស់ពួកគេ។ ការនេះអាស្រ័យលើលក្ខខណ្ឌនានាដែល បានដាក់ដោយតុលាការ។

### បញ្ហាត្រូវបានត្រឡប់មកវិញ ក្រោយការបញ្ជូនបន្តបានជោគជ័យ

នៅមុនសាលក្រមដំបូង ការបញ្ជូនបន្តដែល បានជោគជ័យអាចត្រូវបានបញ្ជូនត្រឡប់ មកវិញទៅតុលាការដែល បញ្ជូនបន្ត។ ការនេះកើតឡើង ប្រសិនបើ៖

- បញ្ហាអំពីសិទ្ធិទទួលបាន ឬភាពសមស្របកើតឡើង,
- ផែនការព្យាបាលមិនអាចរកបាន ឬ
- បុគ្គលនោះដកខ្លួនចេញពីកម្មវិធី។

ប្រសិនបើរឿងនេះកើតឡើង តុលាការ ដោះស្រាយបញ្ហាទាក់ទងនឹងការប្រើឱសថញៀន (Drug Court) នឹងពន្យាពេលលើបញ្ហា នោះត្រឡប់ទៅតុលាការដែលបញ្ជូនបន្តវិញ។

## ព័ត៌មានបន្ថែម

ព័ត៌មានបន្ថែមអំពីតុលាការដោះស្រាយបញ្ហាទាក់ ទងនឹងការប្រើឱសថញៀន (Drug Court) ការបញ្ជូនបន្ត និងព័ត៌មានលម្អិត ទំនាក់ទំនងមាននៅឯ drugcourt.nsw.gov.au។